ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ២១៤ សា-១៧ អអក

ភ្នំពេញ, ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីសម្រេច

# ស្តីពីការកំណត់អត្រាថ្លៃលក់អគ្គិសនីពិសេសនៅរដូវវស្សា សម្រាប់លក់ឲ្យអ្នកកាន់អាជ្ញាបណ្ណ កំពុងភ្ជាប់ចរន្តអគ្គិសនី តាមតង់ស្យុងមធ្យម នៅច្រកព្រំដែនវៀតណាម និងថៃឡង់ដ៍

# អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- បានឃើញប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ៤២១.រថ.អវថ.ប្រក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ការអនុវត្តបន្តពីឆ្នាំ ២០១៧-២០២០
- យោងអាជ្ញាបណ្ណ លេខ០០១.អ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងលិខិតស្នើសុំរបស់អគ្គិសនីកម្ពុជា លេខ ៦០៧១.លស.អក.ផយក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៧
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៣១៤ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៧

## សម្រេច

### ប្រការ១

កំណត់អត្រាថ្លៃលក់អគ្គិសនីពិសេសនៅរដូវវស្សា សម្រាប់លក់ឱ្យអ្នកកាន់អាជ្ញាបណ្ណចែកចាយដែលកំពុងភ្ជាប់ចរន្តអគ្គិសនីតាមតង់ស្យុងមធ្យម នៅច្រកព្រំដែនវៀតណាម និងថៃឡង់ដ៏ មានអត្រាស្មើ 0.099 ដុល្លាអាមេរិកក្នុង១ គីឡូវ៉ាត់ម៉ោង។

### ប្រការ២

អត្រាថ្លៃពិសេសនៅរដូវវស្សា ដែលបានកំណត់ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានប្រើលើសពីមធ្យមភាគនៃការប្រើប្រាស់ ៦ ខែ ដើមឆ្នាំ២០១៧ និងត្រូវអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានទិញក្រោយពីវត្តស្រង់ចុងខែមិថុនា រហូតដល់វត្តស្រង់ចុងខែតុលា ឆ្នាំ២០១៧ ដែលត្រូវនឹងការចេញវិក្កយបត្រនៅចុងខែកក្កដា ដល់ចុងខែតុលា ឆ្នាំ២០១៧ ក្នុងរដូវវស្សាតែប៉ុណ្ណោះ ។



អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**ប្រការ៣**

ការទិញអគ្គិសនីពីអគ្គិសនីកម្ពុជា តាមប្រការខាងលើនេះ អ្នកកាន់អាជ្ញាបណ្ណ ត្រូវរក្សាមេគុណអានុភាព ($\cos\varphi$) នៃការទទួលអគ្គិសនីរបស់ខ្លួនឲ្យឋិតនៅក្នុងកម្រិតគុណភាព $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ មានន័យថា អ្នកកាន់អាជ្ញាបណ្ណ មានសិទ្ធប្រើប្រាស់ថាមពលរ៉េអាក់ទីវ ចេញពីប្រព័ន្ធផ្គត់ផ្គង់របស់អគ្គិសនីកម្ពុជា មិនលើសពីចំនួនកំណត់មួយដែលកំណត់ដោយ $\cos > 0.9$ ឬ $tg < 0.484$ ។ ក្នុងករណីដែលអ្នកកាន់អាជ្ញាបណ្ណ ខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើប្រាស់ថាមពលរ៉េអាក់ទីវ ពីប្រព័ន្ធរបស់អគ្គិសនីកម្ពុជា លើសពីចំនួនកំណត់ អ្នកកាន់អាជ្ញាបណ្ណ ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវ ដែលខ្លួនប្រើប្រាស់លើសនេះ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវ ស្មើនឹង 0.025 $US ក្នុង ១ គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។

**ប្រការ៤**

អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាបណ្ណពាក់ព័ន្ធ ត្រូវមានភារកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ឲ្យមានប្រសិទ្ធភាព។

**ប្រការ៦**

អគ្គិសនីកម្ពុជា មានភារកិច្ចផ្សព្វផ្សាយ អំពីខ្លឹមសារនៃសេចក្ដីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួន ដែលមានការពាក់ព័ន្ធ ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**បណ្ឌិត.ឌី នរិន្ទ**

ចម្លងជូន
-ក្រសួងរ៉ែ និងថាមពល
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
"ដើម្បីជូនជ្រាប"
-អគ្គិសនីកម្ពុជា
"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"
-ឯកសារ-កាលប្បវត្តិ